- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញប្រកាសអន្តរក្រសួងលេខ ៦៥៣ ប្រក.សហវ.សក.ទច.មផ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត ឬធានារ៉ាប់រងតតិយជន
- បានឃើញប្រកាសអន្តរក្រសួងលេខ ៦៥៤ ប្រក.សហវ.សក.ទច.មផ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ
- បានឃើញប្រកាសអន្តរក្រសួងលេខ ៦៥៥ ប្រក.សហវ.ដនស.មផ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០២ ស្តីពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន
- យោងតាមការស្នើរបស់និយ័តករធានារ៉ាប់រងកម្ពុជា

**សម្រេច**

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច ដោយមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **រស់ សីលវ៉ា** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **ម៉ូ ច័ន្ទតីរ្ធ** | អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជា | អនុប្រធាន |
| ៣. ឯកឧត្តម **សុខ គុចហាប់** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ៤. ឯកឧត្តម **លី វណ្ណាសុត្រ** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៥. ឯកឧត្តម **សន សោភ័ណ** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ៦. លោក **សួន វ៉ាន់ហុច** | អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូនផ្លូវគោក ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧. ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចេម ហាក់** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងជាអនុប្រធានអចិន្ត្រៃយ៍អនុកម្មការត្រួតពិនិត្យការអនុវត្តច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៃគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោកក្រសួងមហាផ្ទៃ | សមាជិក |
| ៨. លោក **តឹក សុគឿន** | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុក្រសួងសុខាភិបាល | សមាជិក |
| ៩. លោកស្រីបណ្ឌិត **ហោ សុខឡូនា** | អគ្គនាយករងនៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| ១០. លោក **ហ៊ុយ វ៉ាថារ៉ូ** | ប្រធានសមាគមធានារ៉ាប់រងកម្ពុជា | សមាជិក |



4

| | | |
|---|---|---|
| ១១.លោកឧកញ៉ា **ឈឹម សុភន** | ប្រធានក្រុមប្រឹក្សានាយកសមាគម<br>នៃសមាគមដឹកជញ្ជូនទំនិញផ្លូវគោកកម្ពុជា | សមាជិក |
| ១២.លោកបណ្ឌិត **ឆឹម ចំណាន** | ប្រធានសមាគមដឹកអ្នកដំណើរនិងភស្តុភារកម្ពុជា | សមាជិក |
| ១៣.លោកឧកញ៉ា **ឆារស៍ វ៉ាន់** | ប្រធានសមាគមអ្នកសាងសង់កម្ពុជា | សមាជិក |
| ១៤.លោក **ទូច ម៉េងឡេង** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ<br>នៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| ១៥.លោក **វ៉ា វិជ្ជា** | ប្រធាននាយកដ្ឋានគ្រប់គ្រងអាជ្ញាបណ្ណ<br>និងកិច្ចការគតិយុត្តនៃនិយ័តករធានារ៉ាប់រងកម្ពុជា | សមាជិក |
| ១៦.លោក **ឡាយ ម៉ិងឆាយ** | ប្រធានការិយាល័យសហប្រតិបត្តិការ<br>នៃនិយ័តករធានារ៉ាប់រងកម្ពុជា | ជាលេខាធិការ។ |

**ប្រការ២.-**

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច មានភារកិច្ចដូចខាងក្រោម៖

- ជំរុញការអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច និងការដាក់ទណ្ឌកម្មផាកពិន័យចំពោះបទល្មើសទាំងឡាយដែលកំណត់ដោយច្បាប់និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធជាធរមាន
- ធ្វើអធិការកិច្ច និងការចុះត្រួតពិនិត្យដល់ទីកន្លែងលើការអនុវត្តកាតព្វកិច្ចរបស់ម្ចាស់យានយន្តគ្រប់ប្រភេទ ម្ចាស់ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ និងម្ចាស់ការដ្ឋានសាងសង់ ក្នុងករណីចាំបាច់ តាមលិខិតបញ្ជាបេសកកម្មរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ចែករំលែក និងចងក្រងព័ត៌មាននិងទិន្នន័យអំពីការធានារ៉ាប់រងជាកាតព្វកិច្ច ទាំងផ្នែកទន់ និងផ្នែករឹង ជាប្រចាំ រវាងក្រសួងឬស្ថាប័នដែលជាសមាជិក ដោយផ្តល់របាយការណ៍ប្រចាំគ្រា តាមការកំណត់របស់ក្រុមការងារ
- ផ្សព្វផ្សាយ និងអប់រំសាធារណជន ម្ចាស់យានយន្តប្រកបអាជីវកម្ម ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរ និងម្ចាស់ការដ្ឋានទាំងអស់អំពីកាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវយានយន្ត កាតព្វកិច្ចធានា-រ៉ាប់រងការដឹកជញ្ជូនអ្នកដំណើរ កាតព្វកិច្ចធានារ៉ាប់រងភារៈទទួលខុសត្រូវការដ្ឋាន និងកាតព្វកិច្ចធានារ៉ាប់រងផ្សេងទៀត
- សិក្សា រៀបចំ និងធ្វើវិសោធនកម្មលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធការធានារ៉ាប់រងជាកាតព្វកិច្ច សិក្សានិងផ្តល់យោបល់អំពីតម្រូវការផលិតផលធានារ៉ាប់រងដែលត្រូវកំណត់ជាកាតព្វកិច្ចសម្រាប់អនុវត្តនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- រាយការណ៍អំពីវឌ្ឍនភាពនៃការអនុវត្តការជានាវ៉ាប់រងជាកាតព្វកិច្ចនិងសមិទ្ធផលការងាររបស់ក្រុមការងារជូនរាជរដ្ឋាភិបាលកម្ពុជា តាមរយៈរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បំពេញភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់ប្រធានក្រុមការងារ។

**ប្រការ៣.-**

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការជានាវ៉ាប់រងជាកាតព្វកិច្ចមាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ នៃនិយ័តករធានារ៉ាប់រងកម្ពុជា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ជាលេខាធិការដ្ឋាន ដែលមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- សម្របសម្រួល សិក្សា និងរៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការធានារ៉ាប់រងជាកាតព្វកិច្ច
- សម្របសម្រួល និងតាមដានការងារផ្តល់របាយការណ៍របស់សមាជិកក្រុមការងារ
- សម្របសម្រួល និងរៀបចំកិច្ចប្រជុំ សិក្ខាសាលា ការអប់រំផ្សព្វផ្សាយ និងការចែករំលែកទិន្នន័យព័ត៌មាន
- សម្របសម្រួល និងរៀបចំបូកសរុបរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមការងារ
- បំពេញការងារផ្សេងទៀតតាមការណែនាំរបស់ប្រធានក្រុមការងារ។

**ប្រការ៤.-**

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការជានាវ៉ាប់រងជាកាតព្វកិច្ចត្រូវមានរបបប្រជុំយ៉ាងយូរ ៦ (ប្រាំមួយ) ខែម្តង ក្នុង ១ (មួយ) ឆ្នាំ។ អនុប្រធាន និងសមាជិកក្រុមការងារ ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។ ក្នុងករណីអវត្តមាន អនុប្រធាននិងសមាជិកក្រុមការងារត្រូវជូនដំណឹងនិងចាត់តំណាងចូលរួមប្រជុំជំនួស។

អនុប្រធានក្រុមការងារអាចដឹកនាំកិច្ចប្រជុំ តាមការប្រគល់សិទ្ធិរបស់ប្រធានក្រុមការងារ ។

ប្រធានក្រុមការងារ មានសិទ្ធិកោះអញ្ជើញភាគីពាក់ព័ន្ធផ្សេងទៀតចូលរួមកិច្ចប្រជុំតាមការចាំបាច់។

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការជានាវ៉ាប់រងជាកាតព្វកិច្ចអាចបង្កើតអនុក្រុមការងារបច្ចេកទេសជាសេនាធិការតាមការចាំបាច់។

**ប្រការ៥.-**

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការជានាវ៉ាប់រងជាកាតព្វកិច្ចអាចប្រើប្រាស់កញ្ចប់ថវិការបស់និយ័តករធានារ៉ាប់រងកម្ពុជា សម្រាប់រ៉ាប់រងចំណាយចាំបាច់ក្នុងការអនុវត្តតួនាទីរបស់ក្រុមការងារ។



k

ក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ចអាចប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋ-កិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៦ .-**

ប្រកាសលេខ ៣៨១ សហវ.ប្រក.ន.ធ.ក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤ ស្ដីពីការបង្កើតក្រុមការងារអន្តរក្រសួងដើម្បីអនុវត្តការធានារ៉ាប់រងជាកាតព្វកិច្ច ត្រូវទុកជានិរាករណ៍។

**ប្រការ៧ .-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូប-នីយកម្មនិងសំណង់ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អគ្គនាយកនៃនិយ័តករធានារ៉ាប់រងកម្ពុជានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ[illegible] ខែ [illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] គ.ស.២០២៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងមហាផ្ទៃ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- ក្រសួងយុត្តិធម៌
- ក្រសួងសុខាភិបាល
- ក្រសួងសាធារណការនិងដឹកជញ្ជូន
- ក្រសួងទេសចរណ៍
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត
  នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- និយ័តករធានារ៉ាប់រងកម្ពុជា នៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- ដូចប្រការ១ និងប្រការ៧
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៙៙៚៚

ក្រសួងសាធារណការ និងដឹកជញ្ជូន

លេខ: ០៣៩ សក.ប្រក

ទីស្ដីការគណៈរដ្ឋមន្ត្រី
ចូល
លេខ......1067
ថ្ងៃទី..24..ខែ..02..ឆ្នាំ..26
ម៉ោង....3H 39

# ប្រកាស
## ស្ដីពី
## ទម្រង់និងបែបបទពាក្យស្នើសុំតភ្ជាប់ជាមួយបណ្ដាញលូ

## រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្ដីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២៤/០០៥ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០២៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធទឹកកខ្វក់
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ២២០ អនក្រ.បក ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការដំឡើងនាយកដ្ឋានសំណង់ប្រព័ន្ធចម្រោះទឹកកខ្វក់ ទៅជាអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ ស្ដីពីការប្រែក្លាយនិងដំឡើងវិទ្យាស្ថានជាតិបណ្ដុះបណ្ដាលបច្ចេកទេសសាធារណការ និងដឹកជញ្ជូន ទៅជាវិទ្យាស្ថានតេជោសែនសាធារណការ និងដឹកជញ្ជូន របស់ក្រសួងសាធារណការនិងដឹកជញ្ជូន

- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការដំឡើងនាយកដ្ឋានព័ត៌មានវិទ្យា និងទំនាក់ទំនងសាធារណៈ ទៅជាអគ្គនាយកដ្ឋានបច្ចេកវិទ្យា និងទំនាក់ទំនងសាធារណៈ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសាធារណការនិងដឹកជញ្ជូន

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**ប្រការ១ .-**

ប្រកាសនេះកំណត់អំពីទម្រង់ និងបែបបទពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូ ដើម្បីជំរុញឱ្យបុគ្គលដែលជាម្ចាស់ទីតាំងស្ថិតក្នុងតំបន់ដែលមានប្រព័ន្ធលូស្រាប់និងទើបផ្លាស់ប្តូរថ្មី និងក្នុងតំបន់ទើបកសាងឬរៀបចំប្រព័ន្ធលូថ្មី ត្រូវបំពេញកាតព្វកិច្ចអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះសកម្មភាពពាក់ព័ន្ធការតភ្ជាប់បណ្តាញលូ និងចំពោះអ្នកប្រើប្រាស់ប្រព័ន្ធលូ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់និយមន័យដូចខាងក្រោម៖

**ទីតាំង** សំដៅដល់ទីសាធារណៈ អគារសាធារណៈ លំនៅឋាន លំនៅឋានប្រមូលផ្តុំ បុរីលំនៅឋាន អគារ ឬមណ្ឌលអាជីវកម្មនិងផលិតកម្ម ទីក្រុងរណប រមណីយដ្ឋាន មណ្ឌលកម្សាន្ត ឬទីតាំងប្រហាក់ប្រហែលផ្សេងទៀត។

**ប្រព័ន្ធទឹកកខ្វក់** សំដៅដល់ប្រព័ន្ធលូ ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ឬស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ទីលានគ្រប់គ្រងសំណល់កក់ ការងារប្រព័ន្ធទឹកកខ្វក់ សំណង់សិល្បការ្យទឹកកខ្វក់ ឬឋបនីយភណ្ឌទឹកកខ្វក់ និងសកម្មភាពពាក់ព័ន្ធនឹងទឹកកខ្វក់ផ្សេងទៀត។

**បណ្តាញលូ** សំដៅដល់បណ្តាញលូរួមនិងបណ្តាញលូញែក។

**ប្រព័ន្ធលូ** សំដៅដល់ប្រព័ន្ធលូសាធារណៈ និងប្រព័ន្ធលូឯកជន ដែលមានជាអាទិ៍បណ្តាញលូរួម និង/ឬបណ្តាញលូញែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង បណ្តាញលូខ្នែងរង បណ្តាញ-លូស្អាត់ តំណភ្ជាប់ អណ្តូងលូ។

**ប្រព័ន្ធលូសាធារណៈ** សំដៅដល់ប្រព័ន្ធលូដែលបានអភិវឌ្ឍ សាងសង់ ស្តារឡើងវិញ ដំឡើង ជួសជុល ថែទាំ និង/ឬគ្រប់គ្រងដោយសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់។

**ប្រព័ន្ធលូឯកជន** សំដៅដល់បណ្តាញលូដែលបានសាងសង់ ដំឡើង ជួសជុល ថែទាំ និងប្រតិបត្តិការដោយការវិនិយោគពីវិស័យឯកជន។

**ប្រតិបត្តិករ** សំដៅដល់អង្គភាពដែលត្រូវបង្កើតឡើងដោយរដ្ឋឬក្រុមហ៊ុនឯកជនដែលទទួលបានសិទ្ធិគ្រប់គ្រង ថែទាំ និងប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់ស្របតាមច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ភ្នាក់ងារមានសមត្ថកិច្ច** សំដៅដល់មន្ត្រីដែលត្រូវចាត់តាំងដោយសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ឱ្យចុះតាមដានត្រួតពិនិត្យមើលព្រំកំណត់ខ្សែប្រព័ន្ធលូឬបណ្តាញលូ ទីតាំងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ឬស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ឬអាងចម្រោះទឹកកខ្វក់ អណ្តូងលូ ចំណុចតភ្ជាប់ និងសកម្មភាពពាក់ព័ន្ធផ្សេងទៀត។

**លំនៅឋាន** សំដៅដល់ផ្ទះស្នាក់នៅជាលក្ខណៈឯកជនផ្ទាល់ខ្លួន។

**សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់** សំដៅដល់ក្រសួងសាធារណការនិងដឹកជញ្ជូន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២
## សមត្ថកិច្ច

**ប្រការ៤ .-**

ក្រសួងសាធារណការនិងដឹកជញ្ជូន ដោយមានអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ជាសេនាធិការ មានសមត្ថកិច្ចគ្រប់គ្រង សម្របសម្រួលលើការអនុវត្ត ការត្រួតពិនិត្យ និងការផ្តល់ការអនុញ្ញាត ឬបដិសេធ និងផ្តល់យោបល់បច្ចេកទេស ចំពោះការស្នើសុំតភ្ជាប់បំពង់លូនៃទីតាំងដែលមានផ្ទៃក្រឡាដីសរុបលើសពី ៥០ ០០០ ម៉ែត្រក្រឡា ឬផ្ទៃក្រឡាកម្រាលសំណង់សរុបលើសពី ៣ ០០០ ម៉ែត្រក្រឡា ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៥ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមានអង្គភាពគ្រប់គ្រងប្រព័ន្ធចម្រោះទឹកកខ្វក់នៃមន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត ជាសេនាធិការ មានសមត្ថកិច្ចគ្រប់គ្រង ផ្តល់ការអនុញ្ញាត ឬបដិសេធ និងផ្តល់យោបល់បច្ចេកទេស ចំពោះការស្នើសុំតភ្ជាប់បំពង់លូនៃទីតាំងដែលមានផ្ទៃក្រឡាដីសរុបតិចជាងឬស្មើ ៥០ ០០០ ម៉ែត្រក្រឡា ឬផ្ទៃក្រឡាកម្រាលសំណង់សរុបតិចជាងឬស្មើ ៣ ០០០ ម៉ែត្រក្រឡា និង/ឬការប្រគល់ ឬការធ្វើប្រតិភូកម្មពីក្រសួងស្ថាប័នដែលទទួលបន្ទុកអភិវឌ្ឍន៍ប្រព័ន្ធទឹកកខ្វក់ ដោយអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ប្រការ៦ .-**

ប្រតិបត្តិករដែលទទួលបានសិទ្ធិគ្រប់គ្រង ថែទាំ និងប្រតិបត្តិការប្រព័ន្ធទឹកកខ្វក់នៅក្នុងតំបន់ណាមួយត្រូវអនុវត្តការងារតភ្ជាប់បំពង់លូណាមួយជាមួយបណ្តាញលូឬប្រព័ន្ធលូ ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

## ជំពូកទី៣
## ទម្រង់ និងបែបបទពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូ

**ប្រការ៧ .-**

បុគ្គលដែលជាម្ចាស់ទីតាំងស្ថិតក្នុងតំបន់ដែលមានប្រព័ន្ធលូស្រាប់និងទើបផ្លាស់ប្តូរថ្មី និងក្នុងតំបន់ទើបកសាងឬរៀបចំប្រព័ន្ធលូថ្មី ត្រូវដាក់ពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូ តាមការកំណត់របស់សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់។

ការដាក់ពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូ អាចបំពេញតាមទម្រង់ដោយដៃ ឬតាមប្រព័ន្ធឌីជីថល និងត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារ ដូចខាងក្រោម៖

- ពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូ ចំនួន១ច្បាប់
- ច្បាប់ចម្លងអត្តសញ្ញាណបណ្ណ ឬសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ចំនួន១ច្បាប់

ទម្រង់ពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១ និងទី២ នៃប្រកាសនេះ និង/ឬអាចទាញយកក្នុងគេហទំព័រផ្លូវការរបស់ក្រសួងសាធារណការនិងដឹកជញ្ជូន https://www.mpwt.gov.kh។

**ប្រការ៨ ._**

រាល់ការស្នើសុំតភ្ជាប់ណាមួយជាមួយបណ្តាញលូឬប្រព័ន្ធលូ ត្រូវបំពេញបែបបទដូចខាងក្រោម៖

១-បុគ្គលដែលជាម្ចាស់ទីតាំងត្រូវបំពេញនិងដាក់ពាក្យស្នើសុំតភ្ជាប់ និងភ្ជាប់មកជាមួយនូវឯកសារពាក់ព័ន្ធ ដូចមានចែងក្នុងប្រការ៧នៃប្រកាសនេះ។

២-មន្ត្រី ឬភ្នាក់ងារទទួលបន្ទុក ត្រូវទទួលនិងពិនិត្យពាក្យស្នើសុំតភ្ជាប់និងឯកសារពាក់ព័ន្ធដែលភ្ជាប់មកជាមួយ។

៣-មន្ត្រី ឬភ្នាក់ងារទទួលបន្ទុក ត្រូវសម្របសម្រួលស្នើសុំការអនុញ្ញាតឱ្យជីកផ្លូវថ្នល់ឬចិញ្ចើមផ្លូវពីអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ។

៤-មន្ត្រី ឬភ្នាក់ងារទទួលបន្ទុក ត្រូវរៀបចំកិច្ចសន្យាប្រើប្រាស់ប្រព័ន្ធលូ ព្រមទាំងទទួលកម្រៃសេវាស្នើសុំតភ្ជាប់។

៥-មន្ត្រី ឬភ្នាក់ងារទទួលបន្ទុក ត្រូវចុះអនុវត្តការងារតភ្ជាប់ជូនម្ចាស់ទីតាំង។

សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ ឬប្រតិបត្តិករ ត្រូវអនុវត្តការងារតាមជំហានការងារនីមួយៗស្របតាមការកំណត់ពេលវេលាច្បាស់លាស់ និងផ្តល់លិខិតណាត់ជួបដែលមានគំរូភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ និងទី៤ នៃប្រកាសនេះ ដើម្បីអនុវត្តការងារ។

**ប្រការ៩ ._**

ការបដិសេធការស្នើសុំតភ្ជាប់ ត្រូវអនុវត្តក្នុងករណីណាមួយដូចខាងក្រោម៖

១-ការប្រើប្រាស់សម្ភារៈបរិក្ខារនិងគ្រឿងបង្គុំលូមិនស្របតាមបទដ្ឋានបច្ចេកទេស ឬមិនស្របតាមស្ថានភាពភូមិសាស្ត្រឬទីតាំងតាមការតម្រូវ និងមិនអនុលោមតាមបទប្បញ្ញត្តិបច្ចេកទេសប្រព័ន្ធទឹកកខ្វក់។

២-តំបន់សេដ្ឋកិច្ចពិសេស សួនឧស្សាហកម្ម ឬសួននវានុវត្តន៍ណាមួយដែលមិនសាងសង់អណ្តូងលូសម្រាប់យកសំណាកទឹកសំណល់ដែលធ្វើប្រព្រឹត្តកម្មបឋម ដើម្បីធ្វើតេស្តគុណភាពទឹកមុនពេលតភ្ជាប់ និងបង្ហូរតាមបណ្តាញលូឬប្រព័ន្ធលូ។

៣-តំបន់ឬទីតាំងតម្រូវឱ្យសាងសង់ឬដំឡើងអាងសិបទិកសម្រាប់ស្តុកឬច្រោះទឹកកខ្វក់ ដូចមានចែងក្នុងមាត្រា៥៧នៃច្បាប់ស្តីពីប្រព័ន្ធទឹកកខ្វក់។

៤-តំបន់ឬទីតាំងដែលអាចធ្វើឱ្យខូចមុខងារនៃបណ្តាញលូឬប្រព័ន្ធលូ។

៥-តំបន់ឬទីតាំងមិនសមស្របក្រោយពីទទួលបានការវាយតម្លៃពីសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់។

**ប្រការ១០ ._**

រាល់ការតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូត្រូវបង់កម្រៃសេវាសាធារណៈ ស្របតាមប្រកាសអន្តរក្រសួងរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន។

## ជំពូកទី៤
## បណ្តឹងតវ៉ាចំពោះការបដិសេធមិនឱ្យតភ្ជាប់ជាមួយបណ្តាញលូ

**ប្រការ១១.-**

បុគ្គលដែលមិនសុខចិត្តនឹងការបដិសេធមិនឱ្យតភ្ជាប់ មានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានលិខិតបដិសេធ។ សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ត្រូវសម្រេចលើពាក្យប្តឹងតវ៉ានេះក្នុងរយៈពេល១០(ដប់ប្រាំ)ថ្ងៃ គិតចាប់ពីថ្ងៃទទួលពាក្យប្តឹងតវ៉ា។ បុគ្គលដែលមិនសុខចិត្តនឹងសេចក្តីសម្រេចរបស់សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ មានសិទ្ធិប្តឹងទៅតុលាការមានសមត្ថកិច្ចតាមនីតិវិធីក្នុងរយៈពេល១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសេចក្តីសម្រេចរបស់សមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**ប្រការ១២.-**

បុគ្គលជាម្ចាស់ទីតាំងដែលមិនទាន់ធ្វើការស្នើសុំតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូ ត្រូវធ្វើការស្នើសុំតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូ ក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃ គិតចាប់ពីថ្ងៃដែលសមត្ថកិច្ចគ្រប់គ្រងប្រព័ន្ធទឹកកខ្វក់ជូនដំណឹង។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៤.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកវិទ្យាស្ថានតេជោសែនសាធារណការនិងដឹកជញ្ជូន ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត និងប្រធានអង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ [illegible] ខែ [illegible] ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែ [illegible] ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ប៉េង ពោធិ៍នា**

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធទី១នៃប្រកាសលេខ សក.ប្រក ចុះថ្ងៃទី ខែ ឆ្នាំ២០២...
ស្តីពីទម្រង់និងបែបបទពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូ

គំរូទម្រង់ពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូ**
**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ....................................អាយុ............ទូរសព្ទលេខ............................. អាសយដ្ឋាន៖ ផ្ទះលេខ..................ផ្លូវ.........ប្លុក........ក្រុម/ភូមិ..................ឃុំ/សង្កាត់..................... ក្រុង/ស្រុក/ខណ្ឌ............................រាជធានី/ខេត្ត.......................ជាម្ចាស់ទីតាំងស្នើសុំតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូ។

សូមមេត្តាអនុញ្ញាតតភ្ជាប់ពីទីតាំង............................................ជាមួយបណ្តាញលូឬប្រព័ន្ធលូ ដើម្បីបំពេញតម្រូវការប្រើប្រាស់ប្រចាំថ្ងៃក្នុងគ្រួសារ/អង្គភាព/ផលិតកម្ម/ពាណិជ្ជកម្ម/អាជីវកម្ម និងរួមចំណែកជួយការពារការបំពុលទឹកឬបរិស្ថានធម្មជាតិ។

ថ្ងៃ............ ខែ..............ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅ.......................ថ្ងៃទី........ខែ........ឆ្នាំ២០២......
**ហត្ថលេខាឬស្នាមមេដៃ**

បញ្ជាក់៖
ឈ្មោះភ្នាក់ងារចុះត្រួតពិនិត្យទីតាំង៖.....................................
ថ្ងៃ/ខែ/ឆ្នាំ ចុះត្រួតពិនិត្យទីតាំង៖..........................................
ថ្ងៃ/ខែ/ឆ្នាំ ចុះអនុវត្តការងារតភ្ជាប់៖.......................................

ឧបសម្ព័ន្ធទី២នៃប្រកាសលេខ សក.ប្រក ចុះថ្ងៃទី ខែ ឆ្នាំ២០២...
ស្តីពីទម្រង់និងបែបបទពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូ

**គំរូទម្រង់ពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូ**
**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី/ខេត្ត**.......................

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ...................................អាយុ...........ទូរសព្ទលេខ............................ អាសយដ្ឋាន៖ ផ្ទះលេខ.................ផ្លូវ.........ប្លុក........ក្រុម/ភូមិ.................ឃុំ/សង្កាត់.................... ក្រុង/ស្រុក/ខណ្ឌ............................រាជធានី/ខេត្ត......................ជាម្ចាស់ទីតាំងស្នើសុំតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូ។

សូមមេត្តាអនុញ្ញាតតភ្ជាប់ពីទីតាំង...........................................ជាមួយបណ្តាញលូឬប្រព័ន្ធលូ ដើម្បីបំពេញតម្រូវការប្រើប្រាស់ប្រចាំថ្ងៃក្នុងគ្រួសារ/អង្គភាព/ផលិតកម្ម/ពាណិជ្ជកម្ម/អាជីវកម្ម និងរួមចំណែកជួយការពារការបំពុលទឹកឬបរិស្ថានធម្មជាតិ។

ធ្វើនៅ.......................ថ្ងៃទី........ខែ........ឆ្នាំ២០២......

**ហត្ថលេខាឬស្នាមមេដៃ**

បញ្ជាក់៖
ឈ្មោះភ្នាក់ងារចុះត្រួតពិនិត្យទីតាំង៖....................................
ថ្ងៃ/ខែ/ឆ្នាំ ចុះត្រួតពិនិត្យទីតាំង៖..........................................
ថ្ងៃ/ខែ/ឆ្នាំ ចុះអនុវត្តការងារតភ្ជាប់៖......................................

ឧបសម្ព័ន្ធទី៣នៃប្រកាសលេខ សក.ប្រក ចុះថ្ងៃទី ខែ ឆ្នាំ២០២...
ស្តីពីទម្រង់និងបែបបទពាក្យស្នើសុំតភ្ជាប់ជាមួយបណ្ដាញលូ

**គំរូលិខិតណាត់ជួបអនុវត្តការងារតភ្ជាប់ជាមួយបណ្ដាញលូ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសាធារណការនិងដឹកជញ្ជូន**
**អគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់**

លេខ៖...............................

## លិខិតណាត់ជួបអនុវត្តការងារតភ្ជាប់បណ្ដាញលូ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ....................................មន្ត្រីបច្ចេកទេសនៃអគ្គនាយកដ្ឋានប្រព័ន្ធចម្រោះទឹកកខ្វក់ ទូរសព្ទលេខ.............................. សូមណាត់ជួបលោក/លោកស្រី....................................ដើម្បីចុះត្រួតពិនិត្យទីតាំងតភ្ជាប់ជាមួយបណ្ដាញលូឬប្រព័ន្ធលូចេញពីផ្ទះលេខ.................ផ្លូវ.............ប្លុក........ក្រុម/ភូមិ.................ឃុំ/សង្កាត់....................ក្រុង/ស្រុក/ខណ្ឌ...........................រាជធានី/ខេត្ត.......................។

សូមមេត្តាផ្តល់កិច្ចសហការ ដោយដាក់លេខផ្លូវ និងប្លុកទីតាំងឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការអនុវត្តការងារត្រួតពិនិត្យទីតាំង និងតភ្ជាប់ជាមួយបណ្ដាញលូឬប្រព័ន្ធលូ ឱ្យបានឆាប់រហ័ស ឬអាចទំនាក់ទំនងជាមួយភ្នាក់ងារមានសមត្ថកិច្ចឈ្មោះ........................ទូរសព្ទលេខ......................។

លោក/លោកស្រីអាចអញ្ជើញមកបង់កម្រៃសេវាសាធារណៈតភ្ជាប់ជាមួយបណ្ដាញលូឬប្រព័ន្ធលូដោយផ្ទាល់ ឬតាមប្រព័ន្ធ ធនាគារ..................... ចាប់ពីថ្ងៃទី............ខែ.........ឆ្នាំ២០......នេះតទៅ។

បានចុះពិនិត្យទីតាំងតភ្ជាប់ជាមួយបណ្ដាញលូរួចរាល់ នៅថ្ងៃទី ខែ ឆ្នាំ២០............។

ធ្វើនៅ..........................ថ្ងៃទី........ខែ..............ឆ្នាំ២០២.....
**ហត្ថលេខាភ្នាក់ងារចុះត្រួតពិនិត្យទីតាំង**

ឧបសម្ព័ន្ធទី៤នៃប្រកាសលេខ សក.ប្រក ចុះថ្ងៃទី ខែ ឆ្នាំ២០២...
ស្តីពីទម្រង់និងបែបបទពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូ

**គំរូលិខិតណាត់ជួបអនុវត្តការងារតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានី/ខេត្ត**.........................
**មន្ទីរសាធារណការនិងដឹកជញ្ជូន**.........................

លេខ៖.................................

**លិខិតណាត់ជួបអនុវត្តការងារតភ្ជាប់ជាមួយបណ្តាញលូ**

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................មន្ត្រីបច្ចេកទេសនៃអង្គភាពគ្រប់គ្រងប្រព័ន្ធចម្រោះទឹកកខ្វក់រាជធានី/ខេត្ត................................ទូរសព្ទលេខ.............................សូមណាត់ជួបលោក/លោកស្រី..........................................ដើម្បីចុះត្រួតពិនិត្យទីតាំងតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូចេញពីផ្ទះលេខ..................ផ្លូវ.........ប្លុក........ក្រុម/ភូមិ.................ឃុំ/សង្កាត់...............................ក្រុង/ស្រុក/ខណ្ឌ.............................រាជធានី/ខេត្ត........................។

សូមមេត្តាផ្តល់កិច្ចសហការ ដោយដាក់លេខផ្លូវ និងប្លុកទីតាំងឱ្យបានច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការអនុវត្តការងារត្រួតពិនិត្យទីតាំង និងតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូឱ្យបានឆាប់រហ័ស ឬអាចទំនាក់ទំនងជាមួយភ្នាក់ងារមានសមត្ថកិច្ចឈ្មោះ.........................ទូរសព្ទលេខ......................។

លោក/លោកស្រីអាចអញ្ជើញមកបង់កម្រៃសេវាសាធារណៈតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូដោយផ្ទាល់ ឬតាមប្រព័ន្ធធនាគារ...................... ចាប់ពីថ្ងៃទី............ខែ...........ឆ្នាំ២០......នេះតទៅ។

បានចុះពិនិត្យទីតាំងតភ្ជាប់ជាមួយបណ្តាញលូរួចរាល់ នៅថ្ងៃទី ខែ ឆ្នាំ២០............។

ធ្វើនៅ...........................ថ្ងៃទី........ខែ...............ឆ្នាំ២០២......
**ហត្ថលេខាភ្នាក់ងារចុះត្រួតពិនិត្យទីតាំង**

ឧបសម្ព័ន្ធទី៥នៃប្រកាសលេខ សក.ប្រក ចុះថ្ងៃទី ខែ ឆ្នាំ២០២...
ស្តីពីទម្រង់និងបែបបទពាក្យស្នើសុំតភ្ជាប់ជាមួយបណ្តាញលូ

**គំនូសបំព្រួញអំពីដំណើរការនៃការស្នើសុំតភ្ជាប់ជាមួយបណ្តាញលូឬប្រព័ន្ធលូ**



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation Religion King

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
Ministry of Industry, Science, Technology & Innovation

លេខ: ០១៨ ឧវក.បសវ.ប្រក

ទីស្តីការគណៈរដ្ឋមន្ត្រី
ចូល
លេខ 1202
ថ្ងៃទី 04 ខែ 03 ឆ្នាំ 26
ម៉ោង 10H 38

# ប្រកាស
## ស្តីពី
## ប្រព័ន្ធគ្រប់គ្រងការបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួលនិងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២០/០០៩ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- យោងតាមតម្រូវការចាំបាច់របស់ក្រសួង



៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)-២៣-២១១១៤១
45 Preah Norodom Boulevard, Sangkat Phsar Thmey III, Khan Daun Penh, Phnom Penh, Phone: (855)-23-211141

# សម្រេច
# ជំពូកទី១
# បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ កំណត់ពីប្រព័ន្ធគ្រប់គ្រងការបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម ដើម្បីជានាសុវត្ថិភាព បរិស្ថាន សុខុមាលភាព និងចូលរួមកាត់បន្ថយការបំពុលនិងការប្រែប្រួលអាកាសធាតុ តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងនិងលក្ខណៈបច្ចេកទេស ស្របតាមច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រនិងសិប្បកម្ម ។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណង៖

- បង្កើតវិធានប្រព័ន្ធគ្រប់គ្រងការបំពុល នៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម
- កំណត់កាតព្វកិច្ចរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ សហគ្រាស និងសិប្បកម្ម និងអ្នកគ្រប់គ្រងការបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម
- បង្កើតវិធានប្រព័ន្ធអ្នកគ្រប់គ្រងការបំពុល និងគុណវុឌ្ឍិ តាមរយៈការអភិវឌ្ឍធនធានមនុស្ស។

**ប្រការ៣.-**

វាក្យសព្ទសំខាន់ៗ ត្រូវបានកំណត់និយមន័យនៅក្នុងប្រកាសនេះ ដូចខាងក្រោម៖

- **ឧស្សាហកម្មកម្មន្តសាល** សំដៅដល់រោងចក្រ សហគ្រាស និងសិប្បកម្ម សម្រាប់ផលិត បំប្លែងវត្ថុធាតុដើម ឬផលិតផលពាក់កណ្ដាលសម្រេចឱ្យទៅជាផលិតផលថ្មី ឬ/និង សម្រាប់ធ្វើសកម្មភាពផ្សេងទៀត ដែលមានជាអាទិ៍ ផ្គុំ តម្លើង ជួសជុល ធ្វើតេស្ត វេចខ្ចប់ ប្រកបំពេញ ថែទាំ រក្សាទុក កែលម្អ ដើម្បីបម្រើសេចក្ដីត្រូវការទីផ្សារ។
- **ប្រព័ន្ធគ្រប់គ្រងការបំពុល** សំដៅដល់គោលនយោបាយរបស់ក្រុមហ៊ុន រចនាសម្ព័ន្ធ គ្រប់គ្រងធនធានមនុស្សដែលមានសមត្ថភាព ចំណេះជំនាញជាក់លាក់ បច្ចេកវិទ្យា សម្រាប់ត្រួតពិនិត្យ និងគ្រប់គ្រងការបំពុល។
- **ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ សហគ្រាស និងសិប្បកម្ម** សំដៅដល់ថ្នាក់គ្រប់គ្រងកំពូលក្នុងរោងចក្រ សហគ្រាស និងសិប្បកម្មហើយមានមុខងារទទួលខុសត្រូវរួម ក្នុងការត្រួតពិនិត្យ និងការបង្ការការបំពុល។
- **អ្នកគ្រប់គ្រងការបំពុល** សំដៅដល់បុគ្គល ឬក្រុមការងាររបស់រោងចក្រ សហគ្រាស និងសិប្បកម្មដែលមានកាតព្វកិច្ចពិនិត្យ និងគ្រប់គ្រងការបំពុលតាមផ្នែកមួយនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម ដូចជាខ្យល់ ទឹក សំឡេង រំញ័រ ធូលី។

- **សារធាតុបំពុល** សំដៅដល់សារធាតុ ឬវត្ថុធាតុអ្វីមួយដែលប្រើប្រាស់ និង/ឬកើតចេញពីខ្សែច្រវាក់ផលិតកម្មនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម ក្នុងការផលិតនូវផលិតផលសម្រេចដែលរោងចក្រ សហគ្រាស និងសិប្បកម្មមានផលអវិជ្ជមានដល់បរិស្ថាន។
- **អាងប្រព្រឹត្តកម្ម** សំដៅដល់ប្រព័ន្ធប្រព្រឹត្តកម្មសម្អាតសំណល់រាវ ដើម្បីកាត់បន្ថយសារធាតុពុលដែលចេញមកពីសំណល់ឧស្សាហកម្ម។
- **ខ្សែច្រវាក់ផលិតកម្ម** សំដៅដល់ប្រព័ន្ធបង្គុំ ឧបករណ៍ គ្រឿងចក្រ គ្រឿងម៉ាស៊ីន បម្រើដល់កិច្ចដំណើរការផលិតកម្ម ដែលផលិតចេញជាផលិតផលសម្រេច។
- **សុវត្ថិភាពឧស្សាហកម្ម** សំដៅដល់ការរៀបចំ ការបំពាក់ ការដំណើរការ សម្រាប់សកម្មភាព នៃកិច្ចដំណើរការរោងចក្រ សហគ្រាស និងសិប្បកម្មទាំងឡាយ ដែលបាននិងកំពុងប្រតិបត្តិការដោយមិនបង្កឱ្យមានគ្រោះថ្នាក់ មហន្តរាយដល់មនុស្ស សត្វ ទ្រព្យសម្បត្តិ និងបរិស្ថាន ទាំងក្នុងនិងក្រៅរោងចក្រ សហគ្រាស សិប្បកម្ម និងសាធារណៈ។
- **សំណល់ឧស្សាហកម្ម** សំដៅដល់សំណល់រាវ រឹង ឧស្ម័ន និងសំណល់កកដែលកើតចេញពីដំណើរការផលិតកម្មរបស់រោងចក្រ សហគ្រាស ឬសិប្បកម្ម ហើយអាចជាសំណល់គ្រោះថ្នាក់ ឬសំណល់មិនគ្រោះថ្នាក់។

## ជំពូកទី២
## ប្រព័ន្ធគ្រប់គ្រងការបំពុល

**ប្រការ៤.-**

ប្រព័ន្ធគ្រប់គ្រងការបំពុល ក្នុងឧស្សាហកម្មកម្មន្តសាល មានកំណត់ក្នុងឧបសម្ព័ន្ធទី១ នៃប្រកាសនេះ។

**ប្រការ៥.-**

ប្រព័ន្ធគ្រប់គ្រងការបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម ត្រូវបានបែងចែកជា ៣(បី) ចំណាត់ថ្នាក់ តាមសមត្ថភាពនៃការបញ្ចេញសំណល់រាវនិងការបំពុលខ្យល់ ដូចមានលម្អិតក្នុងឧបសម្ព័ន្ធទី២ នៃប្រកាសនេះ។

**ប្រការ៦.-**

រោងចក្រ សហគ្រាស និងសិប្បកម្មទាំងអស់ ត្រូវរៀបចំទីកន្លែងសម្រាប់ទុកដាក់ដាច់ដោយឡែកពីគ្នានូវសំណល់ឧស្សាហកម្ម វត្ថុធាតុដើម និងសារធាតុពុលដោយមានការបែងចែកតាមយថាប្រភេទមានបិទស្លាកសញ្ញាសុវត្ថិភាព ស្របតាមបទដ្ឋានបច្ចេកទេស និងប្រកបដោយសុវត្ថិភាព។

**ប្រការ៧.-**

ម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម ត្រូវជានារាល់ការបញ្ចេញចោលនូវសំណល់ឧស្សាហកម្មគ្រប់ប្រភេទនិងសារធាតុបំពុល ស្របតាមបទដ្ឋានបច្ចេកទេស ដើម្បីឆ្លើយតបនឹងកម្រិតបទដ្ឋាននៃការបញ្ចេញសំណល់ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ នៃប្រកាសនេះ។

**ប្រការ៨.-**

ម្ចាស់រោងចក្រ សហគ្រាស និងសិប្បកម្ម ត្រូវមានប្លង់និងគំនូសបំព្រួញនៃប្រព័ន្ធគ្រប់គ្រងត្រួតពិនិត្យការបំពុលដោយសំណល់ឧស្សាហកម្មនិងអាងប្រព្រឹត្តកម្មសំណល់រាវតាមបទដ្ឋានបច្ចេកទេស។

**ប្រការ៩.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ សហគ្រាស និងសិប្បកម្ម ត្រូវរៀបចំរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងការបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្មរបស់ខ្លួន ដោយចាត់តាំងបុគ្គល ឬក្រុម ជាអ្នកគ្រប់គ្រងការបំពុលតាមផ្នែកនីមួយៗ។

ការគ្រប់គ្រងការបំពុល ត្រូវរៀបចំតាមស្ថានភាពជាក់ស្តែង។

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ សហគ្រាស និងសិប្បកម្មជាថ្នាក់គ្រប់គ្រងកំពូលនិងទទួលខុសត្រូវរួមលើការត្រួតពិនិត្យការបំពុល។

## ជំពូកទី៣
## គុណវុឌ្ឍិអ្នកគ្រប់គ្រងការបំពុល

**ប្រការ១០.-**

អ្នកគ្រប់គ្រងការបំពុលក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម ដូចមានចែងក្នុងប្រការ៥ ជំពូកទី២ នៃប្រកាសនេះ ត្រូវមានលក្ខណៈសម្បត្តិស្របតាមកម្មវត្ថុនៃប្រព័ន្ធគ្រប់គ្រងការបំពុល ឬមានវិញ្ញាបនបត្រប្រព័ន្ធគ្រប់គ្រងការបំពុល ដែលមានការទទួលស្គាល់ពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

**ប្រការ១១.-**

អនុលោមតាមប្រការ៩ ជំពូកទី២ នៃប្រកាសនេះ ក្រោយពីបានការរៀបចំប្រព័ន្ធគ្រប់គ្រងត្រួតពិនិត្យការបំពុលក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម ក្នុងករណីអ្នកគ្រប់គ្រងមិនមានលក្ខណៈសម្បត្តិស្របតាមកម្មវត្ថុនៃប្រព័ន្ធគ្រប់គ្រងការបំពុល ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ សហគ្រាស និងសិប្បកម្ម ត្រូវស្នើសុំការបណ្តុះបណ្តាលពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ យ៉ាងយូរ៣០(សាមសិប)ថ្ងៃ។

**ប្រការ១២.-**

ក្នុងករណីមានការផ្លាស់ប្តូរអ្នកគ្រប់គ្រងប្រព័ន្ធការបំពុល ឬអ្នកគ្រប់គ្រងប្រព័ន្ធការបំពុលខកខានមិនបានអនុវត្តការងារខាងលើនេះក្នុងរយៈពេល១(មួយ)ឆ្នាំ ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ ត្រូវដាក់ពាក្យស្នើសុំ

ការបណ្តុះបណ្តាលការគ្រប់គ្រងការបំពុលឡើងវិញមកក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ យ៉ាងយូរ ៣០(សាមសិប)ថ្ងៃ បន្ទាប់ពីមានការផ្លាស់ប្តូរ ឬខកខាន។

**ប្រការ១៣.-**

នាយកដ្ឋានបច្ចេកទេសនិងសុវត្ថិភាពឧស្សាហកម្មនៃអគ្គនាយកដ្ឋានឧស្សាហកម្ម ត្រូវរៀបចំផែនការ និងកម្មវិធីបណ្តុះបណ្តាល ស្របតាមប្រព័ន្ធគ្រប់គ្រងការបំពុល។

## ជំពូកទី៤
## ភារកិច្ចអ្នកគ្រប់គ្រងការបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម

**ប្រការ១៤.-**

អ្នកគ្រប់គ្រងការបំពុលសំណល់រាវនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម ត្រូវ៖

- ត្រួតពិនិត្យវត្ថុធាតុដើមដែលបានប្រើប្រាស់នៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម
- ត្រួតពិនិត្យការបញ្ចេញសំណល់រាវឧស្សាហកម្ម និងសារធាតុបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម
- ប្រតិបត្តិ ត្រួតពិនិត្យ និងជួសជុលថែទាំបរិក្ខារប្រព័ន្ធប្រព្រឹត្តកម្មសំណល់រាវ និងសហគមន៍ជុំវិញ
- ធ្វើការវាស់វែងសារធាតុបំពុលដែលបានបង្ហូរចេញ ដោយកត់ត្រាទិន្នន័យ វិភាគកម្រិតជាតិពុលឱ្យបានច្បាស់លាស់
- ពិនិត្យវាយតម្លៃនិងបង្ការហានិភ័យដែលអាចកើតមានឬបានកើតមានដោយចៃដន្យ ជាយថាហេតុ។

**ប្រការ១៥.-**

អ្នកគ្រប់គ្រងការបំពុលខ្យល់នៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម ត្រូវ៖

- ត្រួតពិនិត្យសារធាតុប្រេងឬវត្ថុធាតុដើមដែលបានប្រើប្រាស់ក្នុងប្រតិបត្តិការចំហេះ
- ត្រួតពិនិត្យកន្លែងដែលបញ្ចេញភាគល្អិតៗនិងផ្សែងពុល
- ប្រតិបត្តិ ត្រួតពិនិត្យ និងជួសជុលថែទាំបរិក្ខារប្រព័ន្ធចម្រោះផ្សែងពុលនិងធូលី និងសហគមន៍ជុំវិញ
- ធ្វើការវាស់វែងភាគល្អិត អណ្តែតក្នុងខ្យល់និងផ្សែងពុលដោយកត់ត្រាទិន្នន័យ វិភាគកម្រិតជាតិពុលឱ្យបានច្បាស់លាស់
- ពិនិត្យវាយតម្លៃនិងបង្ការហានិភ័យដែលអាចកើតមានឬបានកើតមានដោយចៃដន្យ ជាយថាហេតុ។

## ជំពូកទី៥
## ភារកិច្ចរបស់ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ សហគ្រាស និងសិប្បកម្ម

**ប្រការ១៦.-**

ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ សហគ្រាស និងសិប្បកម្ម មានកាតព្វកិច្ចដូចតទៅ៖

- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងធនធានមនុស្សដែលមានសមត្ថភាព ចំណេះជំនាញជាក់លាក់ បច្ចេកវិទ្យា សម្រាប់ត្រួតពិនិត្យ និងគ្រប់គ្រងការបំពុល

- ត្រូវចូលរួមឬចាត់បញ្ជូនអ្នកគ្រប់គ្រងការបំពុលចូលរួមវគ្គបណ្តុះបណ្តាលជំនាញតាមកម្មវិធីនៃប្រព័ន្ធអ្នកគ្រប់គ្រងការបំពុល
- រៀបចំរបាយការណ៍អំពីប្រភេទ បរិមាណ ការបញ្ចេញសំណល់ឧស្សាហកម្ម សារធាតុបំពុល និងការផ្តល់របាយការណ៍វិភាគកម្រិតជាតិពុលដែលមានក្នុងសំណល់ឧស្សាហកម្មឱ្យបានច្បាស់លាស់មកអគ្គនាយកដ្ឋានឧស្សាហកម្មនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រៀងរាល់មួយត្រីមាសម្តង ដោយផ្ទាល់ឬតាមប្រព័ន្ធអនឡាញ តាមទម្រង់ដែលនឹងផ្តល់តាមរយៈការជូនដំណឹងរបស់ក្រសួង
- ម្ចាស់ ឬអ្នកគ្រប់គ្រងរោងចក្រ សហគ្រាស និងសិប្បកម្ម ត្រូវបង្កលក្ខណៈងាយស្រួលដល់មន្ត្រីជំនាញបច្ចេកទេសចុះត្រួតពិនិត្យប្រព័ន្ធគ្រប់គ្រងការបំពុល ក្នុងរយៈពេលមួយឆ្នាំម្តង ឬតាមការចាំបាច់។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៧.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៨.-**

នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល និងគ្រប់អង្គភាពក្រោមឱវាទក្រសួង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ច័ន្ទ ៨ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហែម វណ្ណឌី**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- គ្រប់រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៨
- ឯកសារ កាលប្បវត្តិ

ឧបសម្ព័ន្ធនៃប្រកាសលេខ០១៨៤ [illegible] ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦
ស្តីពីប្រព័ន្ធគ្រប់គ្រងការបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម

## ឧបសម្ព័ន្ធទី១

## ឧស្សាហកម្មកម្មន្តសាលដែលត្រូវមានប្រព័ន្ធគ្រប់គ្រង ត្រួតពិនិត្យការបំពុល

| ល.រ | ប្រភេទរោងចក្រ សហគ្រាស និងសិប្បកម្មកម្មន្តសាល |
|---|---|
| ១ | ផ្នែកអាហារ |
| ២ | ផ្នែកភេសជ្ជៈ |
| ៣ | ផ្នែកបារី |
| ៤ | ផ្នែកវាយនភ័ណ្ឌ |
| ៥ | ផ្នែកសម្លៀកបំពាក់ បោកគក់ ជ្រលក់ពណ៌ |
| ៦ | ផ្នែកកាបូប ស្បែកជើង និងផលិតផលពីស្បែក |
| ៧ | ផ្នែកក្រដាស និងផលិតផលិតផលពីក្រដាស |
| ៨ | ផ្នែកបោះពុម្ព |
| ៩ | ផ្នែកកម្មន្តសាលគីមី និងផលិតផលគីមី |
| ១០ | ផ្នែកផលិតផលថ្នាំពេទ្យ |
| ១១ | ផ្នែកផលិតផលពីកៅស៊ូ និងផ្លាស្ទិច |
| ១២ | ផ្នែកឧស្សាហកម្មពីរ៉ែលោហៈ និងអលោហៈ |
| ១៣ | ផ្នែកការផ្គត់ផ្គង់ចំហាយទឹក |
| ១៤ | និងរោងចក្រកម្មន្តសាលដទៃទៀតដែលត្រូវបានរកឃើញថាមានសក្តានុពលបំពុលខ្ពស់ |

ឧបសម្ព័ន្ធនៃប្រកាសលេខ០១០៨ ឧសស.ឧសក.ប្រក.ចុះថ្ងៃទី២៦...ខែមករា...ឆ្នាំ២០២៦
ស្តីពីប្រព័ន្ធគ្រប់គ្រងការបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម

## ឧបសម្ព័ន្ធទី២
## ការចាត់ថ្នាក់ប្រព័ន្ធគ្រប់គ្រងការបំពុល
## ក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម

| ល.រ | ប្រភេទឧស្សាហកម្ម និងសិប្បកម្ម ដែលត្រូវធ្វើចំណាត់ថ្នាក់ | ចំណាត់ថ្នាក់ ប្រព័ន្ធគ្រប់គ្រងការ បំពុល |
|---|---|---|
| ១ | -ឧស្សាហកម្ម សហគ្រាស និងសិប្បកម្មដែលមានការបញ្ចេញសំណល់រាវឧស្សាហកម្មក្នុងបរិមាណធំជាង ឬស្មើ ៤០ម³/ថ្ងៃ និង<br>-ឧស្សាហកម្ម និងសិប្បកម្មដែលមានការបំពុលខ្យល់ ធំជាង ឬស្មើនឹង ៥០០ម³/ម៉ោង មូលដ្ឋាន | ថ្នាក់ទី១ |
| ២ | ឧស្សាហកម្ម សហគ្រាស និងសិប្បកម្មដែលមានការបញ្ចេញតែសំណល់រាវឧស្សាហកម្មក្នុងបរិមាណធំជាង ឬស្មើ ៤០ម³/ថ្ងៃ | ថ្នាក់ទី២ |
| ៣ | ឧស្សាហកម្ម សហគ្រាស និងសិប្បកម្មដែលមានការបញ្ចេញតែឧស្ម័ន ឬ ធូលីក្នុងកម្រិតធំជាង ឬស្មើ ៥០០ម³/ម៉ោង | ថ្នាក់ទី៣ |

ឧបសម្ព័ន្ធនៃប្រកាសលេខ០១៨ [illegible] ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦
ស្តីពីប្រព័ន្ធគ្រប់គ្រងការបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម

## តារាងឧបសម្ព័ន្ធទី៣
## ផ្នែកទី១
## កម្រិតកំណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុលដែលអនុញ្ញាតឱ្យបញ្ចេញចូល | | |
|---|---|---|---|---|---|
| | | | តំបន់ទឹកសារធារណៈ ប្រភេទទី១ | តំបន់ទឹកសារធារណៈ ប្រភេទទី២ | បណ្តាញលូភ្ជាប់ទៅស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់រួម |
| ១ | សីតុណ្ហភាព[1] | $^0C$ | <៤០ | <៤០ | <៤៥ |
| ២ | ពណ៌ (Color) | mg Pt/l | <៥០ | <១៥០ | <៣០០ |
| ៣ | សារធាតុរឹងអណ្តែតក្នុងទឹក (TSS) | mg/l | <៥០ | <១០០ | <២០០ |
| ៤ | pH | | ៦-៩ | ៥,៥-៩ | ៥-៩ |
| ៥ | $BOD_5$ | mg/l | <៣០ | <៦០ | <២០០ |
| ៦ | COD ($Cr_2O_7^{-2}$) | mg/l | <៦០ | <១២០ | <៣០០ |
| ៧ | ប្រេងឬខ្លាញ់ (Oil & grease) | mg/l | <៥ | <១០ | <៣០ |
| ៨ | សាប៊ូ (Detergent) | mg/l | <៥ | <១០ | <៣០ |
| ៩ | អាម៉ូញាក់ ($NH_3$- as N) | mg/l | <៧ | <១០ | <៣០ |
| ១០ | នីត្រាត ($NO_3^{-1}$ as N) | mg/l | <១០ | <២០ | - |
| ១១ | ក្លរក្នុងទំរង់សេរី ($Cl_2$) | mg/l | <១ | <២ | - |
| ១២ | ក្លរជាអ៊ីយ៉ុង (Cl) | mg/l | <៥០០ | <១០០០ | - |
| ១៣ | ផូស្វាត ($PO_4^{-3}$) | mg/l | <២ | <៥ | - |
| ១៤ | អាសូតសរុប (T-N) | mg/l | <២០ | <៥ | - |
| ១៥ | ផូស្វ័រ (T-P) | mg/l | <៤ | <៦ | - |
| ១៦ | អ៊ីដ្រូសែនស៊ុលហ្វីត ($H_2S$) | mg/l | <០,២ | <០,៥ | <១ |
| ១៧ | ម៉ង់កាណែស (Mn) | mg/l | <១ | <៣ | <៥ |
| ១៨ | បរ (B) | mg/l | <១ | <២,៥ | <៥ |
| ១៩ | បារ្យ៉ូម (Ba) | mg/l | <២ | <៥ | <៧ |
| ២០ | ស្យានីតក្នុងទំរង់សេរី ($CN^{-1}$) | mg/l | <០,១ | <០,២ | <១ |
| ២១ | ស្យានីតសរុប (CN) | mg/l | <១ | <១,៥ | <២ |
| ២២ | អាសេនិច (As) | mg/l | <០,០៥ | <០,១ | <០,៥ |
| ២៣ | ដែក (Fe) | mg/l | <១ | <៥ | <២០ |

| | | | | | |
|---|---|---|---|---|---|
| ២៤ | សំណ (Pb) | mg/l | <0,១ | <0,៣ | <0,៥ |
| ២៥ | ស័ង្កសី (Zn) | mg/l | <២ | <៥ | <១0 |
| ២៦ | ទង់ដែង (Cu) | mg/l | <១ | <២ | <៥ |
| ២៧ | ក្រូម ($Cr^6$) | mg/l | <0,0៥ | <0,១ | <0,៥ |
| ២៨ | កាត់ម្ញូម (Cd) | mg/l | <0,0៥ | <0,១ | <0,៥ |
| ២៩ | នីកែល (Ni) | mg/l | <0,២ | <0,៥ | <២ |
| ៣0 | សេលេញ៉ូម (Se) | mg/l | <0,0២ | <0,៥ | <២ |
| ៣១ | បារ៉ត (Hg) | mg/l | <0,00៥ | <0,0១ | <0,0៥ |
| ៣២ | ផេណុល ($C_6H_6O$) | mg/l | <0,៥ | <១ | <៥ |

<u>កំណត់សម្គាល់៖</u>

**តំបន់ទឹកសាធារណៈប្រភេទទី១៖** សំដៅដល់ប្រភពទឹកបិទមានជាអាទិ៍ ស្រះ ត្រពាំង បឹង ទីទំនាប រួមបញ្ចូលទាំងប្រឡាយទឹក អូរ ព្រែក ស្ទឹង ដែលមិនមានចរន្តទឹកហូរនៅរដូវប្រាំង។

**តំបន់ទឹកសាធារណៈប្រភេទទី២៖** សំដៅដល់ប្រភពទឹកចំហមានជាអាទិ៍ សមុទ្រ ទន្លេ ពាម រួមបញ្ចូលទាំងប្រឡាយទឹក ព្រែក ស្ទឹង ដែលមានចរន្តទឹកហូរនៅរដូវប្រាំង។

(-) ៖ ពុំមានកំណត់តម្លៃ

(១)៖ករណីការបញ្ចេញសំណល់រាវឬទឹកដែលប្រើប្រាស់សម្រាប់ការបញ្ចុះកម្តៅម៉ាស៊ីនគ្រឿងចក្រដែលមានបរិមាណលើសពី៥000ម៉ែត្រគូបក្នុងមួយថ្ងៃ សីតុណ្ហភាពទឹកបញ្ចេញអាចអនុញ្ញាតក្នុងកម្រិត ៥ °C (អង្សាសេ)លើសសីតុណ្ហភាពប្រភពទឹកទទួលនៅចំណុចចម្ងាយ២00ម៉ែត្រពីច្រាំងឬចំណុចបញ្ចេញ។

ឧបសម្ព័ន្ធនៃប្រកាសលេខ០១៨៦ ឧ.ក.ស.ស.ប-ប្រកា ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦
ស្តីពីប្រព័ន្ធគ្រប់គ្រងការបំពុលនៅក្នុងរោងចក្រ សហគ្រាស និងសិប្បកម្ម

## តារាងឧបសម្ព័ន្ធទី៣
## ផ្នែកទី២
## កម្រិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុល ដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័ត ចូលទៅក្នុងបរិយាកាស

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតកំណត់ស្តង់ដារ |
|---|---|---|---|
| ១ | ភាគល្អិតនៅក្នុងផ្សែង បញ្ចេញពីប្រភព: | | |
| | - ឡដុត | $mg/m^3$ | <៤០០ |
| | - រោងចក្រផលិតលោហធាតុ | $mg/m^3$ | <៤០០ |
| | - រោងចក្រស៊ីម៉ង់ត៍ កំបោ និងថ្មស្អយ | $mg/m^3$ | <៤០០ |
| | - រោងចក្របេតុងអាស្វាល់ | $mg/m^3$ | <៥០០ |
| ២ | ធូលី ដែលមានភ្ជាប់: | | |
| | - សារធាតុ ស៊ីលីកាត $SiO_2$ | $mg/m^3$ | <១០០ |
| | - សារធាតុ Asbetos | $\mu g/m^3$ | <០,០២៧ |
| | សារធាតុគីមីអសរីរាង្គ : | $mg/m^3$ | |
| ៣ | អាលុយមីញ៉ូម (Al) | $mg/m^3$ | (ធូលី) <៣០០ , (Al) <៥០ |
| ៤ | អាម៉ូញាក់ ($NH_3$) | $mg/m^3$ | <១០០ |
| ៥ | អាង់ទីម៉ូន (Sb) | $mg/m^3$ | <២៥ |
| ៦ | អាសេនិច (As) | $mg/m^3$ | <២០ |
| ៧ | បេរីល្យ៉ូម (Be) | $mg/m^3$ | <០,០០១ |
| ៨ | ក្លរ (Cl) | $mg/m^3$ | <២០ |
| ៩ | អ៊ីដ្រូសែនក្លរីត (HCl) | $mg/m^3$ | <២០០ |
| ១០ | អ៊ីដ្រូសែនភ្លុយអរីត (HF) | $mg/m^3$ | <១០ |
| ១១ | អ៊ីដ្រូសែនស៊ុលភីត ($H_2S$) | $mg/m^3$ | <២ |
| ១២ | កាត់ម្ញ៉ូម (Cd) | $mg/m^3$ | <១ |
| ១៣ | ទង់ដែង (Cu) | $mg/m^3$ | (ធូលី) <៣០០ , (Cu) <២០ |
| ១៤ | សំណ (Pb) | $mg/m^3$ | (ធូលី) <១០០ , (Pb) <៣០ |
| ១៥ | ស័ង្កសី (Zn) | $mg/m^3$ | <៣០ |
| ១៦ | បារត (Hg) | $mg/m^3$ | <០,១ |
| ១៧ | កាបូនម៉ូណូអុកស៊ីត (CO) | $mg/m^3$ | <១០០០ |

| | | | |
|---|---|---|---|
| ១៨ | ស្ពាន់ធ័រឌីអុកស៊ីត ($SO_2$) | mg/m³ | <៥០០ |
| ១៩ | អាស៊ូតអុកស៊ីត (គ្រប់ប្រភេទ) ($NO_X$) | mg/m³ | <១០០០ |
| ២០ | អាស៊ូតអុកស៊ីត (ចេញពីការផលិតអាស៊ីត) ($NO_X$) | mg/m³ | <២០០០ |
| ២១ | អាស៊ីតស៊ុលផួរិច ($H_2SO_4$) | mg/m³ | <៣៥ |
| ២២ | អាស៊ីតនីទ្រិច ($HNO_3$) | mg/m³ | <៧០ |
| ២៣ | ស្ពាន់ធ័រទ្រីអុកស៊ីត ($SO_3$) | mg/m³ | <៣៥ |
| ២៤ | អាស៊ីតផូស្វរិច ($H_3PO_4$) | mg/m³ | <៣ |
| | សារធាតុគីមីសរីរាង្គ : | | |
| ២៥ | អាសេទីឡែនតេត្រាប្រូមីត ($CHBr_2CHBr_2$) | mg/m³ | <១៤ |
| ២៦ | អាក្រូឡេអ៊ីន ($CH_2CHCHO$) | mg/m³ | <១,២ |
| ២៧ | អានីលីន ($C_6H_5NH_2$) | mg/m³ | <១៩ |
| ២៨ | បង់ស៊ីឌីន ($NH_2C_6H_4C_6H_4NH_2$) | mg/m³ | - |
| ២៩ | បង់សែន ($C_6H_6$) | mg/m³ | <៨០ |
| ៣០ | ក្លរូបង់ស៊ិល ($C_6H_3CH_4Cl$) | mg/m³ | <៥ |
| ៣១ | ប៊ុយទិលឡាមិន ($CH_3(CH_2)_2CH_2NH_2$) | mg/m³ | <១៥ |
| ៣២ | ក្រេសូល ((0-,m-,p-)$CH_3C_6H_40H$) | mg/m³ | <២២ |
| ៣៣ | ក្លរូបង់សែន ($C_6H_5Cl$) | mg/m³ | <៣៥០ |
| ៣៤ | ក្លរូហ្វម ($CHCl_3$) | mg/m³ | <២៤០ |
| ៣៥ | ក្លរូពីគ្រីន ($CCl_3NO_2$) | mg/m³ | <០,៧ |
| ៣៦ | O- ឌីក្លរូបង់សែន ($C_6H_4Cl_2$) | mg/m³ | <៣០០ |
| ៣៧ | 1,1 - ឌីក្លរូអេតាន ($CHCl_2CH_3$) | mg/m³ | <៤០០ |
| ៣៨ | ឌីមេទីលស៊ុលហ្វាត ($(CH_3)_2SO_4$) | mg/m³ | <០,៥ |
| ៣៩ | ឌីមេទីលអ៊ីដ្រាហ្ស៊ីន ($(NH_3)_2NNH_2$) | mg/m³ | <១ |
| ៤០ | ឌីនីត្រូបង់សែន ((O-,M-,p-)$C_6H_4(NO_2)_2$) | mg/m³ | <១ |
| ៤១ | អេទីឡែនឌីអាមីន ($NH_2CH_2$-$CH_2NH_2$) | mg/m³ | <៣០ |
| ៤២ | អេទីឡែនក្លរូអ៊ីឌ្រីន ($CH_2ClCH_2OH$) | mg/m³ | <១៦ |
| ៤៣ | អេទីឡែនអុកស៊ីត ($CH_2OCH_2$) | mg/m³ | <២០ |
| ៤៤ | ហ្វ័រម៉ាល់ដេអ៊ីដ ($HCHO$) | mg/m³ | <៦ |
| ៤៥ | មេទីលអាគ្រីឡាត ($CH_2CHCOOCH_3$) | mg/m³ | <៣៥ |
| ៤៦ | មេតាណុល ($CH_3OH$) | mg/m³ | <២៦០ |
| ៤៧ | មេទីលប្រូមីត ($CH_3Br$) | mg/m³ | <៨០ |

| | | | |
|---|---|---|---|
| ៤៨ | ម៉ូណូមេទីលអានីលីន ($C_6H_5NHCH_3$) | $mg/m^3$ | <៩ |
| ៤៩ | នីត្រូបង់សែន ($C_6H_5NO_2$) | $mg/m^3$ | <៥ |
| ៥០ | នីត្រូគ្លីសេរីន ($C_3H_5(NO_2)_3$) | $mg/m^3$ | <៥ |
| ៥១ | នីត្រូតូលូអែន ($NO_2C_6H_4CH_3$) | $mg/m^3$ | <៣០ |
| ៥២ | ផេណុល ($C_6H_5OH$) | $mg/m^3$ | <១៩ |
| ៥៣ | ផេនីលអ៊ីដ្រាហ្សិន ($C_6H_5NHNH_2$) | $mg/m^3$ | <២២ |
| ៥៤ | ពីរីនឌីន ($C_5H_5N$) | $mg/m^3$ | <៣០ |
| ៥៥ | ពីរែន ($C_{16}H_{10}$) | $mg/m^3$ | <១៥ |
| ៥៦ | គ្វីណូន ($C_6H_4O_2$) | $mg/m^3$ | <0,៤ |
| ៥៧ | ស្ទីរ៉ែន ($C_6H_5CHCH_2$) | $mg/m^3$ | <៤២០ |
| ៥៨ | 1,1; 2,2 - តេត្រាក្លរូអេតាន ($Cl_2HCCHCl_2$) | $mg/m^3$ | <៣៥ |
| ៥៩ | តេត្រាក្លរូមេតាន ($CCl_4$) | $mg/m^3$ | <៦៥ |
| ៦០ | តូលូអែន ($C_6H_5CH_3$) | $mg/m^3$ | <៧៥០ |
| ៦១ | តេត្រានីត្រូមេតាន ($C(NO_2)_4$) | $mg/m^3$ | <៨ |
| ៦២ | តូលូអ៊ីឌីន ($CH_3C_6H_4NH_2$) | $mg/m^3$ | <២២ |
| ៦៣ | តូលូអេន 2,4 - ឌីអ៊ីសូស៊ីអាណាត ($CH_3C_6H_3(NOC)_2$) | $mg/m^3$ | <0,៧ |
| ៦៤ | ទ្រីក្លរូអេទីឡែន ($ClCHCCl_2$) | $mg/m^3$ | <១១០ |
| ៦៥ | ស៊ិលីឌិន ($(CH_3)_2C_6H_3NH_2$) | $mg/m^3$ | <៥០ |
| ៦៦ | វីនីលក្លរីត ($CH_2CHCl$) | $mg/m^3$ | <១៥០ |

សូមរក្សាសិទ្ធិនិងបោះពុម្ពដោយនាយកដ្ឋានរាជកិច្ច នៃ
អគ្គនាយកដ្ឋានរាជកិច្ចនិងបណ្ណសារជាតិ
ទីស្តីការគណៈរដ្ឋមន្ត្រី